# សុន្ទរកថា

## ឯកឧត្តមកិត្តិបណ្ឌិត ពេជ្រ ប៊ុនធិន រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ ថ្លែងក្នុងពិធីបើកអង្គសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៨ និង លើកទិសដៅការងារឆ្នាំ២០១៩ របស់ក្រសួងមុខងារសាធារណៈ

ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៩, ភោជនីយដ្ឋានទន្លេបាសាក់២

- *ឯកឧត្តម លោកជំទាវ សមាជិក សមាជិកានៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ជាទីគោរព*
- *ឯកឧត្តម លោកជំទាវ តំណាងគ្រប់ក្រសួង ស្ថាប័ន និងរាជធានី ខេត្ត*
- *ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ថ្នាក់ដឹកនាំក្រសួងមុខងារសាធារណៈ និងមន្ទីរមុខងារសាធារណៈគ្រប់រាជធានី ខេត្ត និង*
- *លោក លោកស្រី អ្នកនាងកញ្ញាទាំងអស់ដែលមានវត្តមាននៅថ្ងៃនេះជាទីស្រលាញ់រាប់អាន*

ក្នុងនាមក្រសួងមុខងារសាធារណៈនិងរូបខ្ញុំផ្ទាល់ ខ្ញុំសូមសំដែងការស្វាគមន៍ និង អរគុណចំពោះវត្តមានដ៏ថ្លៃថ្លារបស់ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញាទាំងអស់ដែលបានចូលរួមក្នុងអង្គសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៨ និងលើកទិសដៅការងារឆ្នាំ២០១៩ របស់ក្រសួងមុខងារសាធារណៈនៅក្នុងថ្ងៃនេះ។ ខ្ញុំសូមថ្លែងអំណរគុណនិងកោតសរសើរដល់ថ្នាក់ដឹកនាំនិងសមាជិកក្រុមការងារទាំងអស់របស់ក្រសួងមុខងារសាធារណៈ ដែលបានខិតខំរៀបចំអង្គសន្និបាតនេះឡើងប្រកបដោយការយកចិត្តទុកដាក់ខ្ពស់ និងបរិយាកាសរីករាយ។

ក្នុងឱកាសនេះ ខ្ញុំសូមរំលឹកជូនឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញាទាំងអស់ជ្រាបថា ក្រសួងមុខងារសាធារណៈ ត្រូវបានបង្កើតឡើងដោយរាជរដ្ឋាភិបាលក្នុងនីតិកាលទី៥ នៃរដ្ឋសភា ដោយព្រះរាជក្រម លេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ ដោយបានដាក់បញ្ចូលគ្នាស្ថាប័នចំនួនបី គឺ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលសាធារណៈ និង សាលាភូមិន្ទរដ្ឋបាល ដើម្បីបំពេញបេសកកម្ម និង ភារកិច្ចក្នុងការដឹកនាំ គ្រប់គ្រង និងអភិវឌ្ឍវិស័យមុខងារសាធារណៈ និងកំណែទម្រង់រដ្ឋបាលសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា ឱ្យឆ្លើយតបទៅនឹងសេចក្តីត្រូវការ

ពិតប្រាកដរបស់ប្រជាជន មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និងការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមកម្ពុជា ក៏ដូចជាក្នុងតំបន់និងពិភពលោក។ ឆ្លើយតបទៅនឹងបេសកកម្មនេះ ក្រសួងមុខងារសាធារណៈបានកំណត់យកនូវបាវចនាបី៖

**១. ការពារផលប្រយោជន៍សាធារណៈ**

**២. ការពារផលប្រយោជន៍ក្រសួង ស្ថាប័ន**

**៣. ការពារផលប្រយោជន៍មន្ត្រី**

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អ្នកនាងកញ្ញា!**

សម្រាប់រយៈពេលប្រាំឆ្នាំកន្លងទៅនេះ ក្រសួងមុខងារសាធារណៈបានសម្រេចនូវសមិទ្ធផលសំខាន់ៗ ដែលមានខ្លឹមសារសង្ខេបដូចខាងក្រោម៖

- បានរៀបចំនិងដាក់ឲ្យអនុវត្តច្បាប់និងលិខិតបទដ្ឋានពាក់ព័ន្ធនឹងការគ្រប់គ្រងនិងអភិវឌ្ឍមន្ត្រីរាជការ រួមមានការកំណត់គោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈ ការពង្រឹងការគ្រប់គ្រងវត្តមានមន្ត្រីរាជការ ការរៀបចំមុខតំណែងនិងរចនាសម្ព័ន្ធក្នុងក្រសួង ស្ថាប័ន ការគ្រប់គ្រងមន្ត្រីរាជការជាគ្រូបង្រៀន ការគ្រប់គ្រងមន្ត្រីកិច្ចសន្យា គ្រូបង្រៀនពុទ្ធិកៈសិក្សា ការកែលម្អនីតិវិធីនៃការបើកផ្តល់បៀវត្ស ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ ការបណ្តុះបណ្តាលមន្ត្រីរាជការ ជាដើម
- បានរៀបចំការដំឡើងបៀវត្សមូលដ្ឋាននិងប្រាក់បំណាច់មុខងារសម្រាប់មន្ត្រីរាជការស៊ីវិល កងកម្លាំងប្រដាប់អាវុធនិងមន្ត្រីអនុរក្សពន្ធនាគារ ប្រាក់ឧបត្ថម្ភសម្រាប់មន្ត្រីរាជការក្នុងវិស័យការបរទេស វិស័យយុត្តិធម៌ គ្រូបង្រៀនពុទ្ធិកៈសិក្សា សមាជិករាជរដ្ឋាភិបាល សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងមន្ត្រីភូមិ មន្ត្រីកិច្ចសន្យា មន្ត្រីនៃការិយាល័យប្រជាពលរដ្ឋ ទីប្រឹក្សាជំនួយការ និងមន្ត្រីឋានៈស្មើ មន្ត្រីបម្រើការងារក្នុងខុទ្ទកាល័យនៃក្រសួង ស្ថាប័ន ប្រាក់សោធននិវត្តន៍សម្រាប់អតីតមន្ត្រីរាជការនិងអតីតយុទ្ធជន ប្រាក់វិភាជន៍គ្រួសារ ប្រាក់ឧបត្ថម្ភមាតុភាពដល់មន្ត្រីរាជការជានារី ប្រាក់តំបន់ដល់មន្ត្រីរាជការក្នុងវិស័យអប់រំនិងសុខាភិបាល
- បានគ្រប់គ្រងផែនការក្របខណ្ឌប្រចាំឆ្នាំ ព្រមទាំងការជ្រើសរើសមន្ត្រីរាជការនិងមន្ត្រីកិច្ចសន្យា
- បានធ្វើនិយ័តកម្មជូនមន្ត្រីរាជការស៊ីវិលដែលខកខានក្នុងការឡើងថ្នាក់និងឋានន្តរស័ក្តិ
- បានធ្វើការពិនិត្យនិងវាយតម្លៃលើការកែសម្រួលមុខតំណែងនិងរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន
- បានត្រួតពិនិត្យនិងតាមដានលើការគ្រប់គ្រង និង ការប្រើប្រាស់មន្ត្រីរាជការតាមក្រសួង ស្ថាប័ន សាលារាជធានី ខេត្ត មន្ទីរ និងអង្គភាពនានា
- បានដាក់ឲ្យអនុវត្តកម្មវិធីកាត់ពន្ធលើប្រាក់បៀវត្សមន្ត្រីរាជការស៊ីវិលដោយស្វ័យប្រវត្តិ
- បានរៀបចំនិងដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងមន្ត្រីកិច្ចសន្យាតាមប្រព័ន្ធព័ត៌មានវិទ្យា

- បានរៀបចំអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការតាមរយៈវគ្គបណ្តុះបណ្តាលរយៈពេលវែង និង រយៈពេលខ្លី នៅសាលាភូមិន្ទរដ្ឋបាល
- បានរៀបចំបើកប្រាក់បៀវត្សទាន់ពេលក្នុងសប្តាហ៍ទី៤ នៃខែតាមប្រព័ន្ធធនាគារ
- បានរៀបចំប្រព័ន្ធចំណាត់ថ្នាក់និងតារាងសន្ទស្សន៍បៀវត្សថ្មី របស់មន្ត្រីរាជការស៊ីវិល កងកម្លាំងប្រដាប់អាវុធ និងមន្ត្រីអនុរក្សពន្ធនាគារឱ្យមានសមធម៌និងសង្គតិភាពនឹងគ្នា
- បានរៀបចំការចងក្រងនិងផ្សព្វផ្សាយព័ត៌មានស្តីពីសេវាសាធារណៈតាមប្រព័ន្ធព័ត៌មានវិទ្យា។

ក្រៅពីនេះ យើងទទួលបានសមិទ្ធផលជាច្រើនផ្សេងៗទៀត ដែលមិនបានលើកឡើងក្នុងសុន្ទរកថានេះ។

គួរបញ្ជាក់ផងដែរថា សមិទ្ធផលដែលទទួលបាន គឺដោយសារភាពជាអ្នកដឹកនាំ រួមជាមួយនិងការប្តេជ្ញាចិត្តដ៏មោះមុត ចំណេះដឹងនិងសមត្ថភាពជំនាញពិតប្រាកដរបស់ថ្នាក់ដឹកនាំ ក៏ដូចជាមន្ត្រីជំនាញគ្រប់ផ្នែក គ្រប់កម្រិតឋានានុក្រមទាំងអស់របស់ក្រសួងមុខងារសាធារណៈ ដែលបំពេញភារកិច្ចឈរលើមូលដ្ឋានអភិក្រមបុរេសកម្ម សកម្ម យោគយល់និងសហការគ្នា ស្មារតីជាក្រុម ការទទួលខុសត្រូវខ្ពស់ទៅតាមជំនាញរៀងៗខ្លួនទាំងថ្នាក់ក្រសួងនិងថ្នាក់មន្ទីរ។ កត្តានេះធ្វើឱ្យក្រសួងមុខងារសាធារណៈបានចូលរួមចំណែកអនុវត្តប្រកបដោយជោគជ័យយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល ក៏ដូចជាការសម្រេចសូចនាករគោលនៃកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ។ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និង ថ្នាក់ដឹកនាំរបស់ក្រសួង ស្ថាប័នដទៃទៀតក៏បានទទួលស្គាល់ និងសម្តែងការកោតសរសើរចំពោះកិច្ចខំប្រឹងប្រែង និង សមិទ្ធផលដែលយើងបានសម្រេចបានជូនប្រជាជន មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និងរាជរដ្ឋាភិបាល។

សមិទ្ធផល និង ការកោតសរសើរទាំងនេះ គឺជាមោទនភាពរបស់យើងទាំងអស់គ្នា ដែលជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការរបស់ក្រសួងមុខងារសាធារណៈ។ ក្នុងនាមក្រសួងមុខងារសាធារណៈ ខ្ញុំបានកត់សម្គាល់កត្តាដ៏ចំបងក្នុងការសម្រេចនូវសមិទ្ធផលជាច្រើនរបស់យើង គឺផ្តើមចេញពីគោលនយោបាយនិងយុទ្ធសាស្ត្រដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាល រួមជាមួយនឹងកិច្ចសហការស្អិតរមួតនិងការគាំទ្រគ្នាទៅវិញទៅមកប្រកបដោយសុធន្ទៈរបស់ក្រសួង ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងន័យនេះ សមិទ្ធផលទាំងនេះគឺមិនអាចផ្តាច់ចេញបានពីការចូលរួមនិងគាំទ្រពីថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃក្រសួង ស្ថាប័នពាក់ព័ន្ធ ពិសេសពីសមាជិក សមាជិកាគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ក្រុមការងារកែទម្រង់ប្រព័ន្ធបៀវត្សរបស់រាជរដ្ឋាភិបាល ក្រុមការងារកំណែទម្រង់រដ្ឋបាលសាធារណៈរបស់ក្រសួង ស្ថាប័ន និងរាជធានី ខេត្ត យន្តការសម្របសម្រួលនិងប្រទាក់ក្រឡាគ្នារបស់លេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមជាមួយបណ្តាដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធនានា។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អ្នកនាងកញ្ញា!**

ក្នុងនាមជាអ្នកដឹកនាំការងារវិស័យមុខងារសាធារណៈនិងកំណែទម្រង់រដ្ឋបាលសាធារណៈ ខ្ញុំសូមបញ្ជាក់ថា ទោះបីជាយើងសម្រេចបានសមិទ្ធផលជាច្រើនហើយក៏ដោយ ក៏យើងនៅមានកិច្ចការជាច្រើនដែលត្រូវធ្វើជាបន្តបន្ទាប់តាមកម្រិតអាទិភាព និង តម្រូវការជាក់ស្តែង ហើយបញ្ហាប្រឈមក៏នៅមានច្រើនទៀតដែរ ដែលតម្រូវឲ្យធ្វើការដោះស្រាយជាបន្ទាន់។ បើយើងក្រឡេកមើលការងារកំណែទម្រង់រដ្ឋវិញ គឺចាប់ពីឆ្នាំ១៩៩៣ មក រាជរដ្ឋាភិបាលកម្ពុជាដែលដឹកនាំដោយ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានខិតខំប្រឹងប្រែងប្រឈមមុខគ្រប់បែបយ៉ាង គ្រប់សមរភូមិទាំងក្នុង និងក្រៅប្រទេស ដោយប្តេជ្ញាចិត្តឥតងាករេក្នុងការធ្វើកំណែទម្រង់ប្រទេសឆ្ពោះទៅកាន់លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស និងសេដ្ឋកិច្ចទីផ្សារ ដើម្បីដឹកនាំប្រទេសឈានទៅរកការកាត់បន្ថយភាពក្រីក្រនិងការអភិវឌ្ឍលើគ្រប់វិស័យដូចសព្វថ្ងៃនេះ។ មកដល់បច្ចុប្បន្ននេះ ប្រទេសជាតិយើងទទួលបានសុខសន្តិភាពពេញលេញ សេដ្ឋកិច្ចមានការរីកចម្រើន កម្រិតជីវភាពរស់នៅរបស់ប្រជាជនក៏មានការកើនឡើងឆាប់រហ័ស។ ប្រាក់បៀវត្សអប្បរមាប្រចាំខែរបស់មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ ត្រូវបានដំឡើងជាបន្តបន្ទាប់រហូតដល់បានច្រើនជាងមួយលានរៀលក្នុងឆ្នាំ២០១៨ និងត្រូវបានបន្តដំឡើងជាបន្តបន្ទាប់ ព្រមទាំងបើកផ្តល់បៀវត្សរៀងរាល់ពីរសប្តាហ៍ម្តងចាប់ពីដើមខែមករា ឆ្នាំ២០១៩ ដែលជាការឆ្លើយតបនឹងការសន្យានិងការប្តេជ្ញាចិត្តខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** និងស្របតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នៅក្នុងនីតិកាលទី៦ នៃរដ្ឋសភា ក្នុងក្របខណ្ឌនៃការបង្កើនបៀវត្ស និងការបើកផ្តល់បៀវត្សឱ្យបានឆាប់រហ័ស ទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាពខ្ពស់។

ទោះយ៉ាងណាយើងពិនិត្យឃើញថា តម្រូវការសម្រាប់ជីវភាពរស់នៅរបស់ប្រជាជន គឺមានការកើនឡើងជានិច្ច និង មិនចេះឈប់ឈរ។ ស្ថានភាពបែបនេះ នាំឱ្យរដ្ឋបាលសាធារណៈរបស់យើងក៏ត្រូវមានការផ្លាស់ប្តូរផងដែរ ដោយប្តូរពីតម្រូវការជាបរិមាណ ទៅជាតម្រូវការផ្នែកគុណភាព ជាពិសេសគុណភាពនៃសេវាសាធារណៈតែម្តង។ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល បានសង្កត់ធ្ងន់លើភាពចាំបាច់នៃការបង្កើនល្បឿនបន្ថែមទៀតក្នុងការកែទម្រង់អភិបាលកិច្ចក្នុងរដ្ឋបាលសាធារណៈ តាមរយៈការបន្តពង្រឹងសមត្ថភាពនិងស័ក្តិសិទ្ធភាពនៃសេវាសាធារណៈ សំដៅបម្រើប្រជាជនឱ្យបានកាន់តែប្រសើរឡើង ក៏ដូចជាលើកកម្ពស់បរិយាកាសធុរកិច្ចនិងបរិស្ថានអំណោយផលសម្រាប់ការវិនិយោគ។ ក្នុងទស្សនវិស័យនេះ រដ្ឋបាលកម្ពុជា ត្រូវតែជារដ្ឋបាល**ស្អាតស្អំ ខ្លាំង ឆ្លាតវៃ និងមានប្រជាជនជាស្នូល**។

ចំណុចនេះ ខ្ញុំចង់បញ្ជាក់ប្រាប់អង្គសន្និបាតថា រដ្ឋបាលសាធារណៈរបស់យើង បានឈានចូលដល់ដំណាក់កាលថ្មីមួយ ដែលតម្រូវឱ្យមានការប្រកួតប្រជែង ការលើកកម្ពស់គុណាធិបតេយ្យ ការវាយតម្លៃគុណភាពនិងសមត្ថភាព ការធ្វើទំនើបកម្មប្រព័ន្ធព័ត៌មានវិទ្យាក្នុងរដ្ឋបាលសាធារណៈ និង ការផ្តល់រង្វាន់លើកទឹកចិត្តសម្រាប់មន្ត្រីឆ្នើម ឬ អង្គភាពឆ្នើម ដើម្បីសម្រេចឱ្យបានសេវាសាធារណៈមួយប្រកបដោយគុណភាពខ្ពស់។ ប្រសិនបើយើងមិនផ្តួចផ្តើមគំនិតឱ្យមានការប្រកួតប្រជែង នោះរដ្ឋបាលសាធារណៈរបស់យើងនឹងមិនមានសមត្ថភាពអាចឆ្លើយតបបាននឹងតម្រូវការនៃការអភិវឌ្ឍរបស់វិស័យឯកជន និង មិនអាចឆ្លើយតបបានទាន់ពេល

វេលានឹងតម្រូវការជាក់ស្តែងរបស់ប្រជាជនឡើយ។ ចំណុចនេះ គឺជាគំនិតផ្តួចផ្តើមកែទម្រង់មួយដ៏ធំក្នុងរដ្ឋបាលសាធារណៈ ដែលត្រូវតម្រង់ទិសឆ្ពោះទៅរកការលើកកម្ពស់គុណផលរបស់មន្ត្រីម្នាក់ៗ និងឱ្យតម្លៃខ្ពស់ទៅលើមន្ត្រីដែលមានសមត្ថភាពជំនាញ ក៏ដូចជាសមត្ថភាពគ្រប់គ្រង និងចាត់ចែងការងាររបស់អង្គភាពនីមួយៗ។ ដើម្បីសម្រេចការងារទាំងនេះ យើងទាំងអស់គ្នាត្រូវមានការទទួលខុសត្រូវខ្ពស់ ក្នុងការអនុវត្តតួនាទី ភារកិច្ច ដោយគិតចាប់តាំងពីការកសាងក្របខណ្ឌគតិយុត្តិ បែបបទនិងនីតិវិធីក្នុងការផ្តល់សេវាសាធារណៈ ការកំណត់ស្តង់ដារសេវាសាធារណៈ ការវាយតម្លៃនិងការផ្តល់ចំណាត់ថ្នាក់ កម្រិតសមត្ថភាពជំនាញ ចំណេះដឹង និងធនធានហិរញ្ញវត្ថុជាដើម។

ខ្ញុំជឿជាក់ថា គំនិតផ្តួចផ្តើមនេះ គឺជាទិសដៅការងារដ៏សំខាន់ដែលក្រសួងមុខងារសាធារណៈ ត្រូវលើកឡើង និង ដាក់បញ្ចូលទៅក្នុងកម្មវិធីការងារជាអាទិភាពរបស់ខ្លួន។ និយាយជារួម គឺយើងត្រូវដឹកនាំការងារកែទម្រង់រដ្ឋបាលសាធារណៈ ដោយតម្រង់ឆ្ពោះទៅរក**ការគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម** ដែលត្រូវដើរស្របគ្នាជាមួយនឹងការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ **ពោលគឺថវិកាផ្អែកលើសមិទ្ធកម្ម** និងដើម្បីគាំទ្រដល់កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

ដោយឡែកក្នុងអង្គសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៨ សម្រាប់រយៈពេលមួយថ្ងៃកន្លះនេះ យើងទាំងអស់គ្នានឹងបានស្តាប់របាយការណ៍ស្តីពីលទ្ធផលការងារ ដែលក្រសួងមុខងារសាធារណៈសម្រេចបាន រួមជាមួយនឹងការពិភាក្សាបញ្ហាប្រឈម ការដាក់ចេញនូវវិធានការដើម្បីដោះស្រាយ ក៏ដូចជាការលើកទិសដៅការងារអាទិភាពសម្រាប់ឆ្នាំ២០១៩ ដែលនឹងធ្វើបទបង្ហាញដោយថ្នាក់ដឹកនាំទទួលបន្ទុកតាមចង្កោមការងារនីមួយៗរបស់ក្រសួងមុខងារសាធារណៈ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា!**

ខ្ញុំសង្ឃឹមថា អង្គសន្និបាតរយៈពេលមួយថ្ងៃកន្លះនេះ គឺជាវេទិកាមួយដ៏សំខាន់សម្រាប់ថ្នាក់ដឹកនាំ មន្ត្រីថ្នាក់គ្រប់គ្រង និងមន្ត្រីជំនាញ បានស្តាប់អំពីរបាយការណ៍នៃលទ្ធផលការងាររបស់ខ្លួន និង ត្រូវចូលរួមពិភាក្សាផ្លាស់ប្តូរមតិយោបល់ និង រួមគ្នាលើកទិសដៅការងារថ្មីៗបន្ថែមទៀត ដើម្បីឱ្យក្រសួងមុខងារសាធារណៈធ្វើការបូកសរុបមតិយោបល់ទាំងអស់ រៀបចំចេញជាសំណើគោលនយោបាយ យុទ្ធសាស្ត្រ និង ទិសដៅការងារអាទិភាពថ្មីៗជូនរាជរដ្ឋាភិបាល ជាពិសេសដើម្បីប្រើប្រាស់ជាធាតុចូលសម្រាប់ផែនការយុទ្ធសាស្ត្រ ២០១៩-២០២៣ របស់ក្រសួងមុខងារសាធារណៈ និងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៩-២០៣០។

ទន្ទឹមនេះ ខ្ញុំសូមអំពាវនាវ និង ណែនាំដល់ថ្នាក់ដឹកនាំ មន្ត្រីថ្នាក់គ្រប់គ្រង និងមន្ត្រីជំនាញទាំងអស់ ដែលមានវត្តមាន ក្នុងអង្គសន្និបាតនាពេលនេះ សូមចូលរួមឱ្យបានពេញលេញរយៈពេលមួយថ្ងៃកន្លះនេះ ស្របតាមរបៀបវារៈដែលកំណត់ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និង សេចក្តីថ្លៃថ្នូរ ជាពិសេសចូលរួមក្នុងសកម្មភាពពិភាក្សាលើបញ្ហាប្រឈមក្នុងការអនុវត្តដែនសមត្ថកិច្ចក្នុងវិស័យមុខងារសាធារណៈ កំណត់វិធានការដ៏សំខាន់ដើម្បីជំនះ រាល់បញ្ហាប្រឈមនានា និងលើកទិសដៅអាទិភាពសម្រាប់អនុវត្តក្នុងឆ្នាំ២០១៩។

ជាទីបញ្ចប់ ក្នុងនាមក្រសួងមុខងារសាធារណៈ និងរូបខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញាទាំងអស់ដែលបានចំណាយពេលវេលាដ៏មានតម្លៃចូលរួម ក្នុងអង្គសន្និបាតនេះ។

ខ្ញុំសូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោក និង ទេវតាឆ្នាំថ្មីព្រះនាមទុង្សាទេវី សូមប្រោសប្រទាន សព្ទសាធុការពរជ័យមហាប្រសើរជូនដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញាទាំងអស់ឱ្យ សម្រេចជោគជ័យគ្រប់ការងារ មានសុភមង្គលក្នុងក្រុមគ្រួសារ និង ជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**ខ្ញុំសូមប្រកាសបើកអង្គសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៨ និងលើកទិសដៅការងារឆ្នាំ២០១៩ ចាប់ពីពេលនេះតទៅ!**

**សូមអរគុណ!**